ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## សម្រេច

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំនិងកំណត់ប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល ។

**មាត្រា២ ..**

អនុក្រឹត្យនេះ មានគោលដៅកំណត់ឱ្យមានការរួមបញ្ចូលតែមួយនូវប្រាក់បំណាច់មុខងារក្នុងវិស័យសុខាភិបាល ប្រាក់បំណាច់ប៉ះពាល់សុខភាពបន្ថែមលើបៀវត្សប្រចាំខែជូនបុគ្គលិកមន្ត្រីសុខាភិបាលធ្វើការងារកំចាត់ជំងឺរបេង ប្រាក់ហានិភ័យតំបន់ និងប្រាក់ហានិភ័យសុខភាពបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល ឱ្យទៅជាប្រាក់បំណាច់មុខងារសុខាភិបាល និង ឱ្យមានការរួមបញ្ចូលតែមួយនូវប្រាក់បំណាច់មុខងាររដ្ឋបាលទូទៅ ប្រាក់បំណាច់ប៉ះពាល់សុខភាពបន្ថែមលើបៀវត្សប្រចាំខែជូនបុគ្គលិកមន្ត្រីសុខាភិបាលធ្វើការងារកំចាត់ជំងឺរបេង ប្រាក់ហានិភ័យតំបន់ និងប្រាក់ហានិភ័យសុខភាពបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល ឱ្យទៅជាប្រាក់បំណាច់មុខងាររដ្ឋបាល។

**មាត្រា៣ ..**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលនិងមន្ត្រីកម្មសិក្សានៃក្រសួងសុខាភិបាល។

**មាត្រា៤ ..**

ប្រាក់បំណាច់មុខងារសុខាភិបាល ជាប្រាក់បំណាច់មុខងារប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការស៊ីវិលកំពុងបំពេញមុខងារក្នុងក្របខណ្ឌមន្ត្រីសុខាភិបាលបឋម ក្របខណ្ឌមន្ត្រីសុខាភិបាលមធ្យម និងក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់នៃក្រសួងសុខាភិបាល ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារសុខាភិបាល (រៀល) |
|---|---|---|
| ១ | គិលានុបដ្ឋាកបឋម | ១៥០ ០០០ |
| ២ | ឆ្មបបឋម | ១៥០ ០០០ |
| ៣ | អ្នកបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្របឋម | ១៥០ ០០០ |
| ៤ | គិលានុបដ្ឋាកមធ្យម | ១៨០ ០០០ |
| ៥ | ទន្តគិលានុបដ្ឋាកមធ្យម | ១៨០ ០០០ |
| ៦ | ឆ្មបមធ្យម | ១៨០ ០០០ |
| ៧ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម | ១៨០ ០០០ |
| ៨ | អ្នកព្យាបាលដោយចលនាមធ្យម | ១៨០ ០០០ |
| ៩ | អនុប្រធានមណ្ឌលសុខភាព | ១៨៥ ០០០ |
| ១០ | អនុប្រធានការិយាល័យមន្ទីររាជធានី ខេត្ត | ១៨៥ ០០០ |
| ១១ | ប្រធានមណ្ឌលសុខភាព | ១៩០ ០០០ |
| ១២ | អនុប្រធានមន្ទីរពេទ្យបង្អែកស្រុក | ១៩០ ០០០ |
| ១៣ | អនុប្រធានការិយាល័យស្រុកប្រតិបត្តិ | ១៩០ ០០០ |
| ១៤ | អនុប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត | ១៩០ ០០០ |
| ១៥ | ប្រធានការិយាល័យមន្ទីររាជធានី ខេត្ត | ១៩០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារសុខាភិបាល (រៀល) |
|---|---|---|
| ១៦ | អនុប្រធានការិយាល័យថ្នាក់កណ្តាល | ១៩០ ០០០ |
| ១៧ | ឆ្មប (បរិញ្ញាបត្រ) | ២០០ ០០០ |
| ១៨ | គិលានុបដ្ឋាក(បរិញ្ញាបត្រ) | ២០០ ០០០ |
| ១៩ | គិលានុបដ្ឋាកឯកទេស | ២០០ ០០០ |
| ២០ | ប្រធានមន្ទីរពេទ្យបង្អែកស្រុក | ២០០ ០០០ |
| ២១ | ប្រធានការិយាល័យស្រុកប្រតិបត្តិ | ២០០ ០០០ |
| ២២ | ប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត | ២០០ ០០០ |
| ២៣ | ប្រធានការិយាល័យថ្នាក់កណ្តាល | ២០០ ០០០ |
| ២៤ | អនុប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | ២០០ ០០០ |
| ២៥ | នាយករងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ២០០ ០០០ |
| ២៦ | ទន្តពេទ្យមធ្យម | ២៥០ ០០០ |
| ២៧ | គ្រូពេទ្យមធ្យម | ២៥០ ០០០ |
| ២៨ | ឱសថការីមធ្យម | ២៥០ ០០០ |
| ២៩ | ទន្តបណ្ឌិត | ៣១០ ០០០ |
| ៣០ | ឱសថការី | ៣១០ ០០០ |
| ៣១ | វេជ្ជបណ្ឌិត | ៣២០ ០០០ |
| ៣២ | ទន្តបណ្ឌិតជំនាញ/ទន្តបណ្ឌិតឯកទេស | ៣៨០ ០០០ |
| ៣៣ | វេជ្ជបណ្ឌិត(ជំនាញ/អនុបណ្ឌិត) | ៣៩០ ០០០ |
| ៣៤ | បណ្ឌិតឱសថសាស្ត្រឯកទេស/ឱសថបណ្ឌិត | ៤០០ ០០០ |
| ៣៥ | វេជ្ជបណ្ឌិតឯកទេស | ៤០០ ០០០ |
| ៣៦ | នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៦៥០ ០០០ |
| ៣៧ | ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | ៦៥០ ០០០ |
| ៣៨ | អនុប្រធានឃ្លាំងឱសថកណ្តាល | ៦៥០ ០០០ |
| ៣៩ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | ៦៥០ ០០០ |
| ៤០ | អនុប្រធានមជ្ឈមណ្ឌលជាតិ | ៦៥០ ០០០ |
| ៤១ | នាយករងមន្ទីរពេទ្យជាតិ | ៦៥០ ០០០ |
| ៤២ | នាយករងវិទ្យាស្ថានជាតិ | ៦៥០ ០០០ |
| ៤៣ | នាយករងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | ៦៥០ ០០០ |
| ៤៤ | អនុប្រធាននាយកដ្ឋាន | ៦៧០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារសុខាភិបាល (រៀល) |
|---|---|---|
| ៤៥ | ប្រធានមជ្ឈមណ្ឌលជាតិ | ៧៥០ ០០០ |
| ៤៦ | នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | ៧៥០ ០០០ |
| ៤៧ | នាយកមន្ទីរពេទ្យជាតិ | ៧៥០ ០០០ |
| ៤៨ | ប្រធានឃ្លាំងឱសថកណ្តាល | ៧៥០ ០០០ |
| ៤៩ | នាយកវិទ្យាស្ថានជាតិ | ៧៥០ ០០០ |
| ៥០ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៧៥០ ០០០ |
| ៥១ | សាស្ត្រាចារ្យមហាបរិញ្ញា | ៧៧០ ០០០ |
| ៥២ | ប្រធាននាយកដ្ឋាន | ៧៨០ ០០០ |
| ៥៣ | សកលវិទ្យាធិការរង | ៧៨០ ០០០ |
| ៥៤ | អគ្គាធិការរង | ៧៩០ ០០០ |
| ៥៥ | អគ្គនាយករង | ៧៩០ ០០០ |
| ៥៦ | សកលវិទ្យាធិការ | ៨០០ ០០០ |
| ៥៧ | អគ្គាធិការ | ៨២០ ០០០ |
| ៥៨ | អគ្គនាយក | ៨២០ ០០០ |

**មាត្រា៥** ._

មន្ត្រីរាជការស៊ីវិលនៃក្របខណ្ឌមន្ត្រីសុខាភិបាលបឋម ក្របខណ្ឌមន្ត្រីសុខាភិបាលមធ្យម និងក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់នៃក្រសួងសុខាភិបាលកំពុងបម្រើការងារក្នុងក្រសួងសុខាភិបាល ដែលត្រូវបានតែងតាំងឱ្យកាន់មុខតំណែងណាមួយក្នុងរចនាសម្ព័ន្ធនៃក្រសួងសុខាភិបាល ត្រូវទទួលបានប្រាក់បំណាច់មុខងារផ្អែកលើប្រភេទក្របខណ្ឌប្រសិនបើប្រាក់បំណាច់មុខងារនៃមុខតំណែងនោះមានកម្រិតទាបជាង។

**មាត្រា៦** ._

ប្រាក់បំណាច់មុខងាររដ្ឋបាល ជាប្រាក់បំណាច់មុខងារប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការស៊ីវិលនៃក្របខណ្ឌភ្នាក់ងាររដ្ឋបាល ក្របខណ្ឌលេខាធិការរដ្ឋបាល ក្របខណ្ឌមន្ត្រីក្រមការ ក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលកំពុងបំពេញមុខងារក្នុងមុខតំណែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាល ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងាររដ្ឋបាល(រៀល) |
|---|---|---|
| ១ | ភ្នាក់ងាររដ្ឋបាល | ១០៥ ០០០ |
| ២ | លេខាធិការរដ្ឋបាល | ១០៥ ០០០ |
| ៣ | មន្ត្រីក្រមការ | ១២៦ ០០០ |
| ៤ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ១៦៤ ០០០ |

**មាត្រា៧** ._

ប្រាក់បំណាច់មុខងារដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ នេះតទៅ។

**មាត្រា៨ ..**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ